# របាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់សិស្សសិក្សាអង់គ្លេសជាភាសាបន្ថែមឬគ្រាមភាសា

## ព័ត៌មានសម្រាប់មាតាបិតាឬអ្នកថែទាំ

ជម្រាបមកដល់មាតាបិតានិងអ្នកថែទាំ

លោកអ្នកទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរចំនួនពីរច្បាប់ ពីសាលារៀនរបស់កូនលោកអ្នកជារៀងរាល់ឆ្នាំ។ របាយការណ៍ទាំងនេះនឹងជួយលោកអ្នកឱ្យយល់ ថាតើកូនលោកអ្នកកំពុងរីកចម្រើនយ៉ាងណាដែរ និងអំពីរបៀបដែលសាលារៀនរបស់កូនលោកអ្នកកំពុងជួយដល់ការសិក្សារបស់កូនលោកអ្នក។ របាយការណ៍នេះនឹងបង្ហាញនូវការរីកចម្រើនរបស់កូនលោកអ្នកនៅក្នុងគ្រប់មុខវិជ្ជាទាំងអស់។

### របាយការណ៍សម្រាប់សិស្សទាំងអស់ដែលសិក្សាអង់គ្លេសជាភាសាបន្ថែមឬគ្រាមភាសា (English as an additional language or dialect (EAL/D))

បើកូនលោកអ្នកកំពុងសិក្សាអង់គ្លេសជាភាសាបន្ថែមឬគ្រាមភាសា របាយការណ៍នេះនឹងបង្ហាញនូវការរីកចម្រើនរបស់កូនលោកអ្នកនៅក្នុងការសិក្សាភាសាអង់គ្លេស និងដំណាក់កាលនៃចំណេះដឹងភាសាអង់គ្លេសនៅគ្រាសព្វថ្ងៃរបស់កូនលោកអ្នក។ ដំណាក់កាលទាំងនេះរួមមាន ចាប់ផ្តើម លេចរូបរាង រីកចម្រើន ឬរឹងមាំ។ សូមអានទំព័រម្ខាងទៀតសម្រាប់សេចក្តីពណ៌នានៃដំណាក់កាលទាំងនេះ។

### របាយការណ៍សម្រាប់សិស្សនៅក្នុងកម្មវិធី EAL/D

បើកូនលោកអ្នកស្ថិតនៅក្នុងកម្មវិធី EAL/D នោះគេនឹងទទួលរបាយការណ៍បន្ថែមមួយជាលាយលក្សណ៍អក្សរពីគ្រូបង្រៀន EAL/D ដោយមានរួមទាំងព័ត៌មានអំពីការរីកចម្រើនរបស់គេនៅក្នុងការសិក្សាភាសាអង់គ្លេស។

### របាយការណ៍សម្រាប់សិស្ស EAL/D ដែលទើបមកដល់ថ្មី

បើកូនលោកអ្នកស្ថិតនៅក្នុងកម្មវិធី EAL/D ហើយបានរៀននៅសាលារៀនអូស្ត្រាលីអស់រយៈពេលបួនត្រីមាសឬតិចជាងនេះ នោះរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់កូនលោកអ្នកនឹងមានរួមទាំងអំពីការរីកចម្រើនរបស់គេនៅក្នុងការសិក្សាអង់គ្លេស ព្រមទាំងការរីកចម្រើនរបស់គេនៅក្នុងមុខវិជ្ជាឯទៀតដែលកំពុងសិក្សា ដោយផ្តល់ជាមតិ ជាជាងការដាក់ពិន្ទុ។

### របាយការណ៍ទាំងឡាយសម្រាប់សិស្ស EAL/D ទើបមកដល់ថ្មីដែលរៀននៅក្នុងមណ្ឌលសិក្សាអង់គ្លេសកម្រិតខ្ពស់ ឬសាលាមធ្យមសិក្សាអង់គ្លេសកម្រិតខ្ពស់។

បើកូនលោកអ្នកចុះឈ្មោះរៀននៅមណ្ឌលសិក្សាអង់គ្លេសយ៉ាងសកម្ម ឬសាលាមធ្យមសិក្សាអង់គ្លេសយ៉ាងសកម្មនោះលោកអ្នកនឹងទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយអំពីការរីកចម្រើនរបស់អ្នកទាំងនោះនៅក្នុងការសិក្សាអង់គ្លេស។ បន្ថែមទៅទៀតនោះ របាយការណ៍នេះនឹងបង្ហាញការរីកចម្រើននៅក្នុងមុខវិជ្ជាទាំងអស់ដែលសិក្សាសម្រាប់ការរៀបចំចូលរៀននៅសាលាមធ្យមសិក្សា។

| ដំណាក់កាលចំណេះដឹងភាសាអង់គ្លេស | |
|---|---|
| **ចាប់ផ្តើម** | សិស្សនៅដំណាក់កាលចាប់ផ្តើម កំពុងចាប់ផ្តើមសិក្សាអង់គ្លេស។ សិស្សទាំងនេះអាចនិយាយភាសាមួយឬច្រើនជាងនេះក្រៅពីអង់គ្លេស ហើយអាចមានសមត្ថភាពអក្ខរកម្មសរសេរជាភាសាដំបូងរបស់ខ្លួន តាមកម្រិតសមស្របនៃអាយុ។ សិស្សទាំងនេះកំពុងចាប់ផ្តើមចូលរួមក្នុងកិច្ចការភាសាសាមញ្ញនៃកម្មវិធីសិក្សា។ |
| **លេចរូបរាង** | សិស្សនៅដំណាក់កាលលេចរូបរាង មានតម្រិះវិជ្ជាអង់គ្លេសដែលរីកចម្រើនជាលំដាប់។ សិស្សទាំងនេះអាចនិយាយភាសាមួយឬច្រើនជាងនេះ ដោយមានរួមទាំងអង់គ្លេសជាគោលការណ៍ ហើយមានតម្រិះវិជ្ជាអង់គ្លេសផ្នែកសរសេររីកចម្រើនជាលំដាប់។ សិស្សទាំងនេះអាចចូលរួមសកម្មភាពក្នុងថ្នាក់រៀន និងរួមប្រាស្រ័យក្នុងការសិក្សានៅពេលផ្តល់ការបង្ហាត់ភាសាសមរម្យ និងពេលបន្ថែមដើម្បីបំពេញសកម្មភាពសិក្សាក្នុងថ្នាក់រៀន។ |
| **រីកចម្រើន** | សិស្សនៅដំណាក់កាលរីកចម្រើនអាចនិយាយភាសាមួយឬច្រើនជាងនេះ ដោយមានរួមទាំងអង់គ្លេសដែលអាចប្រើការបាន និងមានតម្រិះវិជ្ជាសរសេរអង់គ្លេសកាន់តែរីកចម្រើន។ សិស្សទាំងនេះជាអ្នកចូលរួមដ៏សកម្មនៅក្នុងថ្នាក់រៀននិងសកម្មភាពជាប្រចាំរបស់សាលារៀន ហើយអាចចូលរួមក្នុងកិច្ចការសិក្សាដោយទទួលជោគជ័យកាន់តែច្រើនឡើងជាលំដាប់។ភាសាដំបូងរបស់គេគឺជាជំនួយដ៏មានតម្លៃតទៅទៀត នៅក្នុងពេលដែលគេកំពុងបង្កើតការគ្រប់គ្រងលើវេយ្យាករណ៍អង់គ្លេស និងកសាងវាក្យសព្ទរបស់ខ្លួន។ |
| **រឹងមាំ** | សិស្សនៅដំណាក់កាលរឹងមាំអាចនិយាយភាសាមួយឬច្រើនជាងនេះ ដោយមានរួមទាំងអង់គ្លេស ហើយមានតម្រិះវិជ្ជាសរសេរអង់គ្លេសដ៏ល្អ។ សិស្សទាំងនេះជាអ្នកចូលរួមដោយឯករាជ្យនៅក្នុងថ្នាក់រៀននិងសកម្មភាពជាប្រចាំរបស់សាលារៀន ហើយមានសមត្ថភាពខ្លាំងឡើងក្នុងការប្រើអង់គ្លេសដើម្បីចូលរួមក្នុងការសិក្សាដោយសម្រេចបានជោគជ័យជាទូទៅ។ សិស្សទាំងនេះយល់និងបង្កើតអត្ថបទសរសេរនិងនិយាយសម្រាប់គោលបំណងជាក់លាក់មួយចំនួនផ្សេងៗគ្នា ប៉ុន្តែនៅតែត្រូវការការបង្ហាត់បង្រៀនភាសាដែលត្រូវផ្តោតទិសដៅនិងវិធីសាស្ត្រដែលជួយអ្នកសិក្សា EAL/D នៅពេលដែលភាសាថ្នាក់ខ្ពស់នៃមុខវិជ្ជាសិក្សាកាន់តែកើនឡើង។ |

## សេវាបកប្រែភាសាតាមទូរសព្ទ

បើលោកអ្នកចង់បានព័ត៌មានបន្ថែម សូមទាក់ទងសាលារៀន។ បើលោកអ្នកត្រូវការអ្នកបកប្រែភាសាដើម្បីជួយលោកអ្នកក្នុងការទាក់ទងសាលារៀន សូមទូរសព្ទទៅកាន់សេវាបកប្រែភាសាតាមទូរសព្ទ (TIS) ដែលមានលេខ 131 450 ហើយសុំអ្នកបកប្រែភាសាដែលនិយាយភាសារបស់លោកអ្នក។ អ្នកបកប្រែភាសានឹងទូរសព្ទទាក់ទងសាលារៀន ហើយនឹងនៅបន្តតាមខ្សែទូរសព្ទនេះដើម្បីជួយការសន្ទនារបស់លោកអ្នក។ លោកអ្នកនឹងមិនបង់ថ្លៃសេវានេះទេ។